# វីរុសកាវ៉ូណា!(2019-nCoV) ខែមករា!ឆ្នាំ2020

ថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ2020

វីរុសថ្មីដែលគេស្គាល់ថា!វីរុសកូរ៉ូណា!**(2019-nCoV)** គឺជាវីរុសផ្លូវដង្ហើមដែលបានរកឃើញដំបូងបង្អស់នៅទីក្រុងវូហាន, ខេត្តហូបេ, ប្រទេសចិន!។! វីរុសនេះបានបណ្ដាលឲ្យមានមនុស្សរាប់ពាន់នាក់ឆ្លងមេរោគ, ដោយមាន!99 ភាគរយនៃអ្នកឆ្លងនោះនៅក្នុងប្រទេសចិន!។!ប្រទេសផ្សេងទៀត, រួម! ទាំងសហរដ្ឋអាមេរិកផង!បានរកឃើញថានៅមានចំនួនតិចតួច!ប៉ុន្តែចំនួនករណីកើនឡើងចំពោះមនុស្សដែលបានធ្វើដំណើរទៅប្រទេសចិន!។!

## តើវីរុសកាវ៉ូណាឆ្លងដោយវិធីណា?

វីរុសកូរ៉ូណាគឺជាវីរុសផ្លូវដង្ហើម ហើយជាទូទៅត្រូវបានឆ្លងតាមរយៈការបញ្ចេញសារធាតុតាមផ្លូវដកដង្ហើម!(ដូចជាដំណក់ទឹកចេញពីការក្អក ឬ!កណ្ដាស់) នៃមនុស្សដែលបានឆ្លងមេរោគទៅមនុស្សម្នាក់ទៀត!។!ព័ត៌មានអំពីរបៀបវីរុសកូរ៉ូណាឆ្លងគឺនៅមានកំរិតនៅឡើយ ។

## តើអ្វីជារោគសញ្ញារបស់វីរុសកាវ៉ូណា?

វីរុសកាវ៉ូណានេះបង្កការឆ្លងផ្លូវដង្ហើម!(សួត) ។!រោគសញ្ញានៃការឆ្លងនេះរួមមាន៖!

- គ្រុនក្ដៅ
- ក្អក!
- ដង្ហើមខ្លីៗ
- នៅក្នុងករណីធ្ងន់ធ្ងរ, ជម្ងឺរលាកសួត!(ការឆ្លងនៅក្នុងសួត)

ខណៈពេលដែលមនុស្សភាគច្រើនជាសះស្បើយពីការឆ្លងមេរោគនេះ, ការឆ្លងខ្លះអាចបណ្ដាលឲ្យមានជម្ងឺធ្ងន់ធ្ងរ!ឬស្លាប់ក៏មាន!។!មនុស្សវ័យ ចំណាស់!និង!មនុស្សដែលមានបញ្ហាសុខភាពពីមុន!ហាក់ដូចជាមានហានិភ័យខ្ពស់សម្រាប់ជម្ងឺធ្ងន់ធ្ងរនេះ!។

## តើមានវិធីព្យាបាលអ្វីខ្លះ? តើមានថ្នាំបង្ការរោគ (វ៉ាក់សាំង) ឬទេ?

មិនមានថ្នាំព្យាបាលជាក់លាក់ប្រឆាំងនឹងការឆ្លងវីរុសកូរ៉ូណា!**(2019-nCoV)** ទេ!ក្រៅពីការជួយថែទាំ!និង!កាត់បន្ថយរោគសញ្ញា!។!បច្ចុប្បន្ន នេះ!មិនមានថ្នាំបង្ការរោគ!(វ៉ាក់សាំង) ដើម្បីការពារមនុស្សពីការឆ្លងវីរុសកូរ៉ូណា!**(2019-nCoV)** ទេ!។

## តើខ្ញុំអាចការពារខ្លួនខ្ញុំដោយវិធីណា?

ទោះបីហានិភ័យដល់ប្រជាជនរស់នៅរដ្ឋម៉ាស្សាឈូសិតពីវីរុសកូរ៉ូណា!**(2019-nCoV)** មានកម្រិតទាបក៏ដោយ!ក៏ការប្រុងប្រយ័ត្ននៅតែដូច គ្នានឹងការជួយទប់ស្កាត់ជម្ងឺគ្រុនផ្ដាសាយ!និង!ជម្ងឺគ្រុនផ្ដាសាយធំ!អាចជួយការពារប្រឆាំងនឹងវីរុសផ្លូវដង្ហើមផ្សេងទៀត៖

- លាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ!និង!ទឹកក្ដៅឧណ្ហៗយ៉ាងហោចណាស់!20 វិនាទី!។!
- ខ្ទប់ការក្អក!និង កណ្ដាស់របស់អ្នក!។
- នៅផ្ទះប្រសិនបើអ្នកឈឺ!។!

## តើខ្ញុំគួរតែពាក់ម៉ាស់ពេលខ្ញុំចេញទៅក្រៅនៅទីសាធារណៈដែរឬទេ?

ហានិភ័យសុខភាពចំពោះប្រជាជនរស់នៅរដ្ឋម៉ាស្សាឈូសិតមានកម្រិតទាប!ហើយនៅពេលនេះ!យើងមិនផ្ដល់អនុសាសន៍ឲ្យមនុស្សពាក់ ម៉ាស់នៅពេលពួកគេនៅទីសាធារណៈឡើយ!។!ម៉ាស់អាចមានប្រយោជន៍នៅក្នុងកន្លែងខ្លះដូចជា!បន្ទប់រង់ចាំនៅគ្លីនិក!ដើម្បីការពារអ្នក! ដែលមានជម្ងឺផ្លូវដង្ហើមពីការឆ្លងដល់អ្នកដទៃទៀត!។!មិនមានភស្តុតាងពិតប្រាកដដែលថាការពាក់ម៉ាស់ជួយការពារអ្នកពាក់នោះនៅក្រៅ! កន្លែងថែទាំសុខភាពនោះទេ!។!

## តើអ្នកធ្វើតេស្តមនុស្សសម្រាប់វីរុសការ៉ូណាដោយវិធីណា?

ការធ្វើតេស្តរកមើលវីរុសកូរ៉ូណា!**(2019-nCoV)** អាចធ្វើបានតែនៅតាមរយៈមន្ទីរពិសោធន៍សុខភាពសាធារណៈរដ្ឋម៉ាស្សាឈូសិត!និង មជ្ឈមណ្ឌលការពារ!និង ទប់ស្កាត់ជម្ងឺឆ្លង!(CDC) ប៉ុណ្ណោះ!។!អ្នកផ្តល់សេវាថែទាំសុខភាពណាមួយដែលសង្ស័យថាមានជនណាម្នាក់ត្រូវ! បានឆ្លងវីរុសកូរ៉ូណា!**(2019-nCoV)** គួរតែទូរស័ព្ទទាក់ទងក្រសួងសុខភាពសាធារណៈរដ្ឋម៉ាស្សាឈូសិតដើម្បីពិភាក្សាពីការធ្វើតេស្ត! តាមរយៈទូរស័ព្ទលេខ៖!(617) 983-6800 ។!

## តើខ្ញុំគួរតែត្រូវឲ្យគេធ្វើតេស្តរកមើលវីរុសការ៉ូណាឬទេ?

មានតែមនុស្សដែលបាននៅកន្លែងមានវីរុសកូរ៉ូណា!**(2019-nCoV)** កំពុងតែកើតេ!ីងប៉ុណ្ណោះ, ឬបាននៅជិតអ្នកណាម្នាក់ដែលផ្ទុកវីរុសនោះ!ហើយ! កំពុងតែមានរោគសញ្ញាដូចជម្ងឺគ្រុនផ្តាសាយធំ!គួរតែត្រូវធ្វើតេស្ត ។!

## តើខ្ញុំគួរតែធ្វើដូចម្តេច ប្រសិនបើខ្ញុំបានទៅលេងកន្លែងដែលមានវីរុសការ៉ូណាកំពុងតែកើតេ ីង ឬប្រសិនបើខ្ញុំបាននៅជិតអ្នកណាម្នាក់ដែលផ្ទុកវីរុសការ៉ូណានោះ?

គិតត្រឹមថ្ងៃទី៦ ខែកុម្ភៈ!ឆ្នាំ2020, ប្រសិនបើអ្នកបាននៅកន្លែងដែលមានវីរុសកូរ៉ូណា!**(2019-nCoV)** កំពុងតែកើតេ ីង, ឬអ្នកបាននៅជិតអ្នកណា! ម្នាក់ដែលផ្ទុកវីរុសនោះ, អ្នកអាចត្រូវបានគេស្នើសុំឲ្យជៀសសវាងទាក់ទងមនុស្សដទៃទៀតមួយផ្នែកខ្លះ!ឬទាំងស្រុង, អាស្រ័យលើលទ្ធភាពនៃការប៉ះពាល់របស់អ្នក!។!អ្នកក៏គួរតែ៖!

- តាមដានសុខភាពរបស់អ្នកអស់រយៈពេល!14ថ្ងៃ!បន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់អ្នក!។
- មើលសញ្ញា!និង!រោគសញ្ញាទាំងនេះ៖!
    a. គ្រុនក្តៅ
    b. ក្អក!
    c. ដង្ហើមខ្លីៗ ឬពិបាកដកដង្ហើម
- រោគសញ្ញាដំបូងផ្សេងទៀតអាចរងាស្រៀវស្រាញ, ឈឺខ្លួនប្រាណ, ឈឺបំពង់ក, ឈឺក្បាល, រាគរូស, ចង់ក្អួតចង្អោរ/ក្អួត និង!ហៀរសំបោរ!។
- ប្រសិនបើអ្នកមានរោគសញ្ញាទាំងនេះ!សូមទូរស័ព្ទទាក់ទងវេជ្ជបណ្ឌិតរបស់អ្នក ។!
- មុនទៅជួបវេជ្ជបណ្ឌិតរបស់អ្នក!ត្រូវតែប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអំពីអ្នកអាចបានប៉ះពាល់វីរុសកូរ៉ូណា!។

## តើខ្ញុំអាចរៀនបន្ថែមទៀតអំពីវីរុសការ៉ូណា (2019-nCov) នៅទីណា?

សម្រាប់ព័ត៌មានថ្មីៗ, សូមចូលមើលគេហទំព័ររបស់ក្រសួងសុខភាពសាធារណៈ៖!www.mass.gov/2019coronavirus.

ព័ត៌មានលំអិត!និងគោលការណ៍ណែនាំបន្ថែមទៀតអាចរកបានពីមជ្ឈមណ្ឌលការពារ!និង!ទប់ស្កាត់ជម្ងឺឆ្លង៖ https://www.cdc.gov/coronavirus.

## សម្រាប់សំណួរផ្សេងៗ

ទាក់ទងវេជ្ជបណ្ឌិត, គ្លីនិក, ឬក្រុមប្រឹក្សាសុខភាពមូលដ្ឋានរបស់អ្នក!(នៅក្នុងសៀវភៅទូរស័ព្ទក្រោមរដ្ឋាភិបាលមូលដ្ឋាន) ។!

ទាក់ទងការិយាល័យក្រសួងសុខភាពសាធារណៈនៃផ្នែកជម្ងឺឆ្លង!និង!មន្ទីរពិសោធន៍វិទ្យាសាស្ត្រតាមរយៈលេខ៖!(617) 983-6800 ។